# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងពាណិជ្ជកម្ម**

លេខ ៤៧៤៣ ព.ណ.ករ....

ថ្ងៃ ចន្ទ ១១កើត ខែ កត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ ២០២១

## សេចក្តីជូនដំណឹង

ក្រសួងពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា មានកិត្តិយសសូមជម្រាបជូនដំណឹងដល់សាធារណជនទូទៅឲ្យបានជ្រាបថា៖ គណៈកម្មការរៀបចំព្រឹត្តិការណ៍ពិព័រណ៍ VIDEX 2021 ដែលគាំទ្រដោយនាយកដ្ឋានសេដ្ឋកិច្ចនៃក្រសួងការពារជាតិវៀតណាម នឹងរៀបចំពិធីតាំងពិព័រណ៍ "**Vietnam Defence – Economics Exposition 2021**" ដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី១៤ ដល់ ១៧ ខែធ្នូ ឆ្នាំ២០២១ នៅទីក្រុងហាណូយ តាមរយៈអនឡាញ។

ក្នុងឱកាសនេះ គណៈកម្មការរៀបចំពិព័រណ៍ VIDEX 2021 សូមអញ្ជើញក្រុមហ៊ុនកម្ពុជា ដែលកំពុងធ្វើធុរកិច្ចលើផ្នែកសិប្បកម្ម, ឧស្សាហកម្ម និងសេវាកម្ម ដើម្បីចូលរួមក្នុងព្រឹត្តិការណ៍ពិព័រណ៍ខាងលើពីចម្ងាយ។ ក្រសួងពាណិជ្ជកម្ម ក្នុងនាមជាអ្នកសម្របសម្រួល ជាមួយស្ថានទូតសាធារណរដ្ឋសង្គមនិយមវៀតណាមប្រចាំនៅរាជធានីភ្នំពេញ សូមអញ្ជើញលោក លោកស្រីដែលជាពាណិជ្ជករ សិប្បករ ឧស្សាហករ សេវាករ និងសាធារណជនទូទៅដែលមានចំណាប់អារម្មណ៍ចង់ចូលរួមក្នុងព្រឹត្តិការណ៍ពិព័រណ៍ខាងលើ សូមចូលទៅកាន់គេហទំព័រ www.videx.vn ឬ ទាក់ទងលោក Le Bien Cuong ទីប្រឹក្សាពាណិជ្ជកម្ម តាមរយៈទូរស័ព្ទ +855 977 831 922, email: kh@moit.gov.vn ។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកនាយកដ្ឋានកិច្ចការពិព័រណ៍ នៃអគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម ក្រសួងពាណិជ្ជកម្ម តាមរយៈអាសយដ្ឋាន៖ ដីឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ។ ទូរស័ព្ទលេខ៖០១៧ ៩៦០ ២០០/ ០៨៧ ៧៥៥ ៥៥១ ឬអ៊ីម៉ែល៖ chousetha@gmail.com /ritatong19@gmail.com។

សូមអរគុណ !

ព្រះរាជាណាចក្រកម្ពុជា * ក្រសួងពាណិជ្ជកម្ម *